ក្រសួងការបរទេស នៃប្រទេសជប៉ុន

សេចក្តីថ្លែងការណ៏

ថ្ងៃទី ៧ ខែសីហា ឆ្នាំ ២០១៤

**សេចក្តីថ្លែងការណ៍របស់រដ្ឋមន្ត្រីក្រសួងការបរទេស នៃប្រទេសជប៉ុន**
**ស្តីអំពីការជំនុំជម្រះក្តីខ្មែរក្រហម :**
**សាលក្រមប្រឆាំងអតីតមេដឹកនាំជាន់ខ្ពស់ នៃរបបខ្មែរក្រហម**

១. កាលពីថ្ងៃទី ៧ ខែសីហា (ពេលវេលានៅប្រទេសកម្ពុជា និងប្រទេសជប៉ុន) អង្គជំនុំជម្រះសាលាដំបូង នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានប្រកាសសាលក្រមផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិតប្រឆាំងនឹងលោក នួន ជា និងលោក ខៀវ សំផន អតីតមេដឹកនាំជាន់ខ្ពស់ នៃរបបខ្មែរក្រហម ។

២. ការជំនុំជម្រះក្តីខ្មែរក្រហម គឺជាជំហានដ៏សំខាន់ឆ្ពោះទៅបញ្ចប់ជាស្ថាពរនូវដំណើរការស្វែងរកសន្តិភាពនៅប្រទេសកម្ពុជា ហើយនឹងរួមចំណែកដល់ការនាំមកនូវយុត្តិធម៌ និងការពង្រឹងនីតិរដ្ឋនៅក្នុងប្រទេសនេះ ។ ហេតុដូច្នេះប្រទេសជប៉ុនបាននិងកំពុងដើរតួនាទីនាំមុខមួយនៅក្នុងសហគមន៍អន្តរជាតិ ក្នុងការផ្តល់ការគាំទ្រចំពោះការជំនុំជម្រះក្តីនេះ និងស្វាគមន៍វឌ្ឍនភាព នៃដំណើរការជំនុំជម្រះក្តី ។

៣. ប្រទេសជប៉ុនមានសេចក្តីសង្ឃឹមយ៉ាងមុតមាំថា ការជំនុំជម្រះក្តីនឹងបន្តដំណើរការប្រកបដោយភាពរលូន ហើយបញ្ចប់បេសកកម្មរបស់ខ្លួនប្រកបដោយភាពឆាប់រហ័ស និងជោគជ័យ ដោយយកចិត្តទុកដាក់គិតគូរដល់វ័យកាន់តែចាស់ជរារបស់ជនជាប់ចោទ និងជនរងគ្រោះ ។

(ចប់)

* សេចក្តីប្រកាសព័ត៌មានដើមត្រូវបានផ្សព្វផ្សាយនៅថ្ងៃទី ៧ ខែសីហា